**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ០២៥៧ ព.ណ.ករ.ស.ម

ថ្ងៃ សុក្រ ៧កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០២១

**ជម្រាបមក**

**លោក/លោកស្រីប្រធាន ក្រុមហ៊ុន អេច ជី ប៊ី គ្រុប**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើរថយន្ត និងគ្រឿងបន្លាស់ម៉ាក "**JEEP**" ដែលមានម៉ូដែលភ្ជាប់មកជាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **អេច ជី ប៊ី គ្រុប**។

**យោង:**- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

- លិខិតរបស់ក្រុមហ៊ុន **អេច ជី ប៊ី គ្រុប** ចុះថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ២០២០
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន FCA US LLC. ចុះថ្ងៃទី ០៨ ខែតុលា ឆ្នាំ ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/២០២៨៨/០៤ ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ ២០១៣។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើរថយន្ត និងគ្រឿងបន្លាស់ពាក់ម៉ាកខាងលើក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **អេច ជី ប៊ី គ្រុប** ដែលទទួលបានពីក្រុមហ៊ុន FCA US LLC. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រា និងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាពរយៈពេល ០២(ពីរ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន FCA US LLC. ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះ អ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មាន ល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

*<u>ចម្លងជូន:</u>*

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**អគ្គនាយកដ្ឋាន សេវាពាណិជ្ជកម្ម**
**នាយកដ្ឋានកម្មសិទ្ធិបញ្ញា**
**ការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម**

# កំណត់បង្ហាញ
## ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ

- **កម្មវត្ថុ៖** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើរថយន្តម៉ាក **“JEEP”**
- **អ្នកស្នើសុំ៖ ក្រុមហ៊ុន អេច ជី ប៊ី គ្រុប**
- **យោង៖** គោលការណ៍ឯកភាព**ឯកឧត្តមរដ្ឋមន្ត្រី** ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០២០

ដោយមានចំណារឯកភាពឯកឧត្តមរដ្ឋមន្ត្រី គួរធ្វើការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើម៉ាក ជូន។

**ប្រធានការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម**

04.01.2021

**លុយ សុផល្លា**

| **យោបល់ឯកឧត្តមអគ្គនាយក** 27-1-21 2:20 | **យោបល់អនុប្រធាននាយកដ្ឋាន** |
| --- | --- |
| **ម៉ុម ថាណា** 2-2-21 | **គោរពជូន**<br>យោងមាត្រា៣ និង១១ នៃច្បាប់ម៉ាក និងឯកសារតម្រូវដែលបានដាក់មកនាងខ្ញុំ/ខ្ញុំបាទយល់ឃើញថា ក្រសួងអាចអនុញ្ញាតឲ្យធ្វើការ កត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខបាន តាមការស្នើសុំ ។<br>សូមលោកប្រធាន ឯកឧត្តមអគ្គនាយក ឯកឧត្តម/លោកជំទាវ រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ មេត្តាពិនិត្យ និងសម្រេច តាមការ គួរ។<br>04.01.21 |
| **យោបល់របស់ឯកឧត្តម/លោកជំទាវ រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ** 2/2/21 | **យោបល់ប្រធាននាយកដ្ឋាន** |
| ឯកភាព<br>**រដ្ឋលេខាធិការ**<br>4/2/21<br>**អ៊ុក_ប្រ៊ុជា** | **យោងគោលការណ៍ឯកភាពរបស់ ឯកឧត្តមរដ្ឋមន្ត្រី៖** ..........<br>សូម ឯកឧត្តមអគ្គនាយក ឯកឧត្តម/លោកជំទាវ រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ មេត្តាពិនិត្យ និងសម្រេច ដោយក្តីអនុគ្រោះ។<br>27 JAN 2021<br>**សួន_វិជ្ជា** |